**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១២៩៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## វិធានការសុខាភិបាលដើម្បីទប់ស្កាត់និងឆ្លើយតប ការឆ្លងរាលដាលជាអន្តរជាតិនៃជំងឺនៅតាមច្រកចេញចូល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកំណត់និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកព្រំដែនទ្វេភាគី ច្រកតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ២១២ អនក្រ.បក ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១[illegible] ស្តីពីការគ្រប់គ្រងសន្តិសុខអាកាសចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី៤ ខែកញ្ញា [illegible]

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងកំណត់អំពីវិធានការសុខាភិបាលអនុវត្តដោយមន្ត្រីចត្តាឡីស័ក ដើម្បីទប់ស្កាត់និងឆ្លើយតបគ្រោះអាសន្នបន្ទាន់ចំពោះសុខភាពសាធារណៈដែលជាកង្វល់ជាតិនិងអន្តរជាតិ នៅតាមច្រកចេញចូល។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅ៖

- ពង្រឹងសមត្ថភាពគ្រប់គ្រងលើគ្រោះអាសន្នបន្ទាន់ចំពោះសុខភាពសាធារណៈដែលជាកង្វល់ជាតិ និងអន្តរជាតិ ដើម្បីកាត់បន្ថយហានិភ័យដល់សុខភាពសាធារណៈ
- ចាត់វិធានការសុខាភិបាលជាបន្ទាន់ ក្នុងករណីមានគ្រោះអាសន្នបន្ទាន់ចំពោះសុខភាពសាធារណៈ ដែលជាកង្វល់ជាតិនិងអន្តរជាតិ ដើម្បីការពារសុខភាពប្រជាជន
- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នពាក់ព័ន្ធជាតិនិងអន្តរជាតិ តាមរយៈយន្តការត្រួតពិនិត្យតាមដាន និងវាយតម្លៃ លើគ្រោះអាសន្នបន្ទាន់ ចំពោះសុខភាពសាធារណៈ ដែលជាកង្វល់ជាតិ និងអន្តរជាតិ។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពត្រួតពិនិត្យសុខភាពនិងអនាម័យ អនុវត្តចំពោះគ្រប់អ្នកដំណើរដែលសង្ស័យថាអាចចម្លងជំងឺ ដែលចេញចូលតាមច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ ចំពោះយានដឹកជញ្ជូនដែលសង្ស័យថាអាចចម្លងជំងឺ ដែលចេញចូលតាមច្រកទ្វារខាងលើនេះ នឹងត្រូវបានត្រួតពិនិត្យផ្នែកអនាម័យនិងការចម្លងរោគដោយមន្ត្រីចត្តាឡីស័ករបស់ក្រសួងសុខាភិបាលនៅក្នុងករណីដែលមានការផ្ទុះការរាតត្បាតជំងឺឆ្លងក្នុងប្រទេសឬអន្តរជាតិ។

**មាត្រា៤ .-**

វាក្យសព្ទបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះមាននិយមន័យ ដូចមានចែងនៅក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយអនុក្រឹត្យនេះស្រាប់។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា៥ .-**

ក្រសួងសុខាភិបាលជាស្ថាប័នមានសមត្ថកិច្ចក្នុងការចាត់វិធានការសុខាភិបាលដើម្បីទប់ស្កាត់និងឆ្លើយតបគ្រោះអាសន្នបន្ទាន់ចំពោះសុខភាពសាធារណៈដែលជាកង្វល់ជាតិនិងអន្តរជាតិ នៅតាមច្រកចេញចូលក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្នុងករណីចាំបាច់ ក្រសួងសុខាភិបាលត្រូវសហការជាមួយនឹងក្រសួងស្ថាប័នពាក់ព័ន្ធជាតិនិងអន្តរជាតិ ក្នុងការអនុវត្តវិធានការសុខាភិបាលឱ្យមានប្រសិទ្ធភាពខ្ពស់។

## ជំពូកទី៣
## វិធានការសុខាភិបាល

**មាត្រា៦ ..**

ក្រសួងសុខាភិបាលត្រូវចាត់តាំងមន្ត្រីជំនាញចត្តាឡីស័ក ដើម្បីធ្វើការត្រួតពិនិត្យ តាមដាន វាយតម្លៃ ផ្តល់ព័ត៌មាន និងអនុវត្តវិធានការសុខាភិបាល។ ក្នុងករណីចាំបាច់ មន្ត្រីចត្តាឡីស័កត្រូវអនុវត្តវិធានការសុខាភិបាល ចំពោះអ្នកដំណើរនិងការីនៃយានដឹកជញ្ជូនដូចជា ការដាក់ឱ្យនៅដាច់ដោយឡែក ឬការបង្ការវេជ្ជសាស្ត្រផ្សេងៗ ក្នុងគោលបំណងកាត់បន្ថយហានិភ័យដែលបណ្តាលមកពីគ្រោះអាសន្នបន្ទាន់សុខភាពសាធារណៈ ដែលជាកង្វល់ជាតិនិងអន្តរជាតិ។

នីតិវិធីនៃការអនុវត្តវិធានការសុខាភិបាលរបស់មន្ត្រីចត្តាឡីស័ក ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។

## ជំពូកទី៤
## កម្រៃសេវា

**មាត្រា៧ ..**

កម្រៃសេវាត្រួតពិនិត្យនិងការអនុវត្តវិធានការសុខាភិបាល ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសុខាភិបាលនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៥
## ទណ្ឌកម្ម

**មាត្រា៨ ..**

អ្នកដំណើរឬការីនៃយានដឹកជញ្ជូនណាដែលគេចវេះមិនឱ្យមន្ត្រីចត្តាឡីស័កធ្វើការត្រួតពិនិត្យ ឬមិនសហការជាមួយនឹងមន្ត្រីចត្តាឡីស័កក្នុងការអនុវត្តវិធានការសុខាភិបាល ឬមិនបំពេញតាមបែបបទដែលមានកំណត់ក្នុងអនុក្រឹត្យនេះ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ពី ២០០០០០(ពីរសែន)រៀលដល់ ១ ០០០ ០០០ (១លាន)រៀល ទៅតាមទំហំនៃបទល្មើស និងតម្រូវឱ្យអនុវត្តវិធានការសុខាភិបាល។

ការទទួលពិន័យអន្តរការណ៍នេះមិនធ្វើឱ្យជនដែលប្រព្រឹត្តបទល្មើសរួចផុតពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដែលមានចែងនៅក្នុងច្បាប់និងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានឡើយ។

ជនណាដែលក្លែងបន្លំឯកសារពាក់ព័ន្ធសុខភាព ក្នុងគោលបំណងគេចវេះពីការអនុវត្តវិធានការចត្តាឡីស័ក ត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។

ក្នុងករណីដែលអ្នកដំណើរឬការីនៃយានដឹកជញ្ជូនមិនព្រមអនុវត្តតាមបទប្បញ្ញត្តិនៃកថាខណ្ឌខាងលើ មន្ត្រីចត្តាឡីស័កត្រូវសហការជាមួយនឹងអាជ្ញាធរពាក់ព័ន្ធដើម្បីបដិសេធការចេញចូលព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៩ ..**

មន្ត្រីចត្តាឡីស័កណាមួយពុំគោរពតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវប្រឈមនឹងវិធានការរដ្ឋបាល ដូចមានចែងក្នុងច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១០ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១១ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធ

**នៃអនុក្រឹត្យលេខ ១២៩. អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០១៥**
**ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់និងឆ្លើយតបការឆ្លងរាលដាល**
**ជាអន្តរជាតិនៃជំងឺនៅតាមច្រកចេញចូល**

## និយមន័យនៃវាក្យសព្ទបច្ចេកទេស

- ច្រកចេញចូល សំដៅដល់ទីតាំងឬកន្លែងដែលមានការត្រួតពិនិត្យរបស់អង្គភាពចម្រុះ ដើម្បីពិនិត្យមើលការចេញចូលព្រះរាជាណាចក្រកម្ពុជា ជាលក្ខណៈអន្តរជាតិ និងសកម្មភាពរបស់អ្នកដំណើរជាតិនិងអន្តរជាតិ មធ្យោបាយដឹកជញ្ជូន នៅតាមច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ ការកំណត់និយមន័យនៃច្រកទ្វារនីមួយៗខាងលើនេះ គឺមានចែងក្នុងជំពូកទី២និងជំពូកទី៣នៃអនុក្រឹត្យលេខ៦៤ អនក្រ.បក្រ ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកំណត់និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។
- យានដឹកជញ្ជូន សំដៅដល់យន្តហោះ នាវា រថភ្លើង យានផ្លូវគោក ឬយានដឹកជញ្ជូនផ្សេងៗទៀតដែលធ្វើដំណើរជាអន្តរជាតិ។
- វិធានការសុខាភិបាល សំដៅដល់របៀបចាត់ការដើម្បីបង្ការទប់ស្កាត់ការរាលដាលនៃជំងឺឬការចម្លងរោគ។
- ចត្តាឡីស័ក សំដៅដល់ការរឹតបន្តឹងសកម្មភាពឬការញែកចេញដោយឡែកពីបុគ្គលផ្សេងទៀតនូវបុគ្គលដែលសង្ស័យថាមានជំងឺឆ្លង។/.